# ច្បាប់ធ្វើការនៃកម្មវិធីផ្តល់ជំនួយម្ហូបអាហារនៃរដ្ឋកាលីហ្វ័រនីញ៉ា (CFAP)

ដើម្បីទទួលជំនួយបណ្ណ័ទិញម្ហូបនៅក្រោមកម្មវិធីផ្តល់ជំនួយម្ហូបអាហារនៃរដ្ឋកាលីហ្វ័រនីញ៉ា (California Food Assistance Program ឬ CFAP) គឺមានច្បាប់ធ្វើការដែលលោកអ្នកត្រូវអនុវត្តតាម ។ ចាប់ផ្តើមពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៩ លោកអ្នកមិនអាចទទួលជំនួយបណ្ណ័ទិញម្ហូបឡើយ លើកលែងតែលោកអ្នកបំពេញតាមច្បាប់ធ្វើការនេះ ឬលោកអ្នកត្រូវបានលើកលែងដោយមិនបាច់ធ្វើតាមច្បាប់នេះ ។

បើសិនជាលោកអ្នកទទួលជំនួយពីកម្មវិធីជួយឱ្យធ្វើការនិងទទួលខុសត្រូវចំពោះកូននៃរដ្ឋកាលីហ្វ័រនីញ៉ា (California Work Opportunity and Responsibility to Kids ឬ CalWORKs) លោកអ្នកត្រូវតែធ្វើតាមច្បាប់ជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការនៃកម្មវិធី CalWORKs ដើម្បីមានសិទ្ធិទទួលជំនួយពីកម្មវិធី CFAP ។ ក៏ប៉ុន្តែ លោកអ្នកអាចត្រូវបានលើកលែងមិនបាច់ធ្វើតាមច្បាប់ធ្វើការនៃកម្មវិធី CalWORKs និងកម្មវិធី CFAP សំរាប់មូលហេតុទាំងឡាយដែលអ្នកកាន់សំណុំរឿងនៃខណ្ឌរបស់លោកអ្នកអាចពន្យល់ជូន ។ បើសិនជាលោកអ្នកមិនធ្វើតាមច្បាប់ជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការនេះទេ ហើយបើសិនជាលោកអ្នកមិនត្រូវបានលើកលែង ជំនួយពីកម្មវិធី CFAP របស់លោកអ្នកអាចត្រូវបានបញ្ឈប់សំរាប់ពេលយ៉ាងតិចណាស់មួយខែ បីខែ ឬប្រាំមួយខែ ។

បើសិនជាលោកអ្នកមិនបានទទួលជំនួយពីកម្មវិធី CalWORKs ទេ លោកអ្នកត្រូវតែធ្វើតាមការតម្រូវឱ្យធ្វើការនៃកម្មវិធី CFAP សំរាប់អ្នកមិនទទួលជំនួយ CalWORKs ។ បណ្ណ័ទិញម្ហូបរបស់លោកអ្នកនឹងបញ្ឈប់ បើសិនជានៅក្នុងកំឡុងពេល៣៦ខែមានពេល៣ខែដែលលោកអ្នកមិនធ្វើតាមច្បាប់តម្រូវឱ្យធ្វើការសំរាប់អ្នកមិនទទួលជំនួយ CalWORKs លើកលែងតែលោកអ្នកត្រូវបានគេលើកលែងមិនបាច់ធ្វើតាមច្បាប់នេះ ។

<u>លោកអ្នកមិនបាច់ធ្វើតាមការតម្រូវឱ្យធ្វើការនៃកម្មវិធី CFAP សំរាប់អ្នកមិនទទួលជំនួយ CalWORKs បើសិនជាលោកអ្នក</u> :

- មានអាយុតិចជាង១៨ឆ្នាំ ឬយ៉ាងតិចណាស់អាយុ៥០ឆ្នាំ
- មានផ្ទៃពោះ
- រស់នៅក្នុងក្រុមគ្រួសារដែលទទួលជំនួយបណ្ណ័ទិញម្ហូបដែលមានក្មេងម្នាក់នៅក្នុងបន្ទុក
- មានភារៈកិច្ចទទួលខុសត្រូវសំរាប់កិច្ចថែរក្សាមនុស្សដែលមានភាពពិការម្នាក់
- មិនអាចធ្វើការបានពីព្រោះតែមានបញ្ហាផ្នែកសុខភាពរូបកាយ ឬសតិអារម្មណ៍
- ទទួលប្រាក់កម្រៃសំរាប់អ្នកមិនមានការងារធ្វើ ឬលោកអ្នកបានដាក់ពាក្យសុំប្រាក់កម្រៃសំរាប់អ្នកគ្មានការងារធ្វើ ប៉ុន្តែលោកអ្នកមិនទាន់បានទទួលនៅឡើយទេ
- ចូលរួមតាមពេលវេលាទៀងទាត់ជាមូលដ្ឋាននៅក្នុងកម្មវិធីព្យាបាលការញៀនថ្នាំញៀនស្រវឹង ឬការប្រមឹក
- ជាសិស្សសិក្សាពាក់កណ្តាលពេល ។

<u>លោកអ្នកអាចអនុវត្តតាមការតម្រូវឱ្យធ្វើការនៃកម្មវិធី CFAP សំរាប់អ្នកមិនទទួលជំនួយ CalWORKs ដោយ</u> :

- ធ្វើការចំនួន២០ម៉ោងឬច្រើនជាងក្នុងមួយសប្តាហ៍ជាមួយការងារដែលមានប្រាក់បង់ ។ ការងារនេះគឺមានបញ្ចូលទាំងជាមុខរបរផ្ទាល់ខ្លួន និងការងារដែលទទួលប្រាក់បង់ឱ្យជារបស់របរ ។
- ចូលរួមនៅក្នុងការងារសំរាប់អ្នកទទួលជំនួយសុខុមាលភាពតាមចំនួនម៉ោងដែលបានតម្រូវ ។ ខណ្ឌអាចពន្យល់ប្រាប់លោកអ្នកថាតើ ការងារសំរាប់អ្នកទទួលជំនួយសុខុមាលភាពនេះជាអ្វី ឬ
- ចូលរួមជាមួយសកម្មភាពធ្វើការដែលបានអនុញ្ញាតសំរាប់ពេលយ៉ាងតិចណាស់២០ម៉ោងក្នុងមួយសប្តាហ៍ ។ ខណ្ឌរបស់លោកអ្នកអាចពន្យល់ថាតើ សកម្មភាពការងារអ្វីដែលត្រូវបានអនុញ្ញាតឱ្យ ។

<u>បើសិនជាជំនួយនៃកម្មវិធី CFAP របស់លោកអ្នកបញ្ឈប់ពីព្រោះតែលោកអ្នកមិនធ្វើតាមច្បាប់សំរាប់អ្នកមិនទទួលជំនួយ CalWORKs លោកអ្នកអាចទទួលជំនួយឡើងវិញ បើសិនជានៅក្នុងកំឡុងពេល៣០ថ្ងៃ លោកអ្នក</u> :

- ធ្វើការចំនួន៨០ម៉ោង ឬច្រើនជាង
- ចូលរួមជាមួយការងារសំរាប់អ្នកទទួលជំនួយសុខុមាលភាពតាមចំនួនម៉ោងដែលបានតម្រូវ
- ចូលរួមជាមួយសកម្មភាពការងារដែលអនុញ្ញាតសំរាប់ពេល៨០ម៉ោង ឬច្រើនជាង ឬ
- ត្រូវបានក្លាយទៅជាអ្នកដែលត្រូវបានគេលើកលែងឱ្យសំរាប់មូលហេតុណាមួយដូចមានចុះនៅខាងលើ ។

បើសិនជាលោកអ្នកទទួលជំនួយនៃកម្មវិធី CFAP សាឡើងវិញ ហើយបន្ទាប់មកឈប់ធ្វើតាមច្បាប់សំរាប់អ្នកមិនទទួលជំនួយ CalWORKs សំរាប់មូលហេតុទាំងឡាយដោយគិតបញ្ចូលទាំងការបញ្ឈប់ការងារជាបណ្តោះអាសន្នពីការងាររបស់លោកអ្នក ឬការបន្ថយចំនួនម៉ោងធ្វើការរបស់លោកអ្នក លោកអ្នកអាចទទួលជំនួយពីកម្មវិធី CFAP ចំនួនបីខែបន្តបន្ទាប់គ្នា ។ បន្ទាប់ពីពេលនោះមក លោកអ្នកអាចទទួលជំនួយពីកម្មវិធី CFAP តែបើសិនជាលោកអ្នកធ្វើតាមច្បាប់សំរាប់អ្នកមិនទទួលជំនួយ CalWORKs ឬក៏ត្រូវបានលើកលែងឱ្យសំរាប់មូលហេតុណាមួយដូចមានចុះនៅខាងលើ ។

លោកអ្នកត្រូវតែធ្វើតាមច្បាប់ធ្វើការនៃកម្មវិធីបណ្ណ័ទិញម្ហូបផងដែរ បើមិនដូច្នោះទេពាក្យដាក់សុំរបស់លោកអ្នកអាចត្រូវបានបដិសេធ ឬក៏បណ្ណ័ទិញម្ហូបរបស់លោកអ្នកអាចត្រូវបានបញ្ឈប់សំរាប់ពេលយ៉ាងតិចណាស់មួយខែ បីខែ ឬប្រាំមួយខែ ។ ច្បាប់ធ្វើការងារនេះមានបញ្ចូលទាំង :

- ការរក្សានូវការណាត់ពេលជួប
- ទទួលនូវការងារដែលគួរទទួលធ្វើបាន
- មិនប្តូរម៉ោងធ្វើការរបស់លោកអ្នកទៅតិចជាង៣០ម៉ោងក្នុងមួយសប្តាហ៍
- ធ្វើតាមច្បាប់ជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការនៅក្រោមកម្មវិធីជួយឱ្យធ្វើការនិងទទួលខុសត្រូវចំពោះកូននៃរដ្ឋកាលីហ្វ័រនីញ៉ា (California Work Opportunity and Responsibility to Kids ឬ CalWORKs)
- មិនលះបង់ការងារ ឬ
- ចូលរួមនៅក្នុងបេសកកម្មធ្វើការងារ ឬហ្វឹកហ្វឺនដែលយើងបានបញ្ជូនលោកអ្នកឱ្យទៅ ។